Click here for English version

# បំបាត់ហានិភ័យនៃការធ្វើប្រតិបត្តិការដែលមានតម្លៃខ្ពស់

BRED BANK CAMBODIA

The smarter way to bank.



សេចក្តីណែនាំរបស់អ្នកចំពោះសេវាកម្ម **Escrow របស់ធនាគារ ប្រេដ**

## អ្វីទៅជាសេវាកម្ម “escrow”?

ទោះបីជាមនុស្សភាគច្រើនកម្រមានឱកាសប្រើប្រាស់សេវាកម្ម escrow ក៏ដោយ សេវាកម្មនេះពិតជាឧបករណ៍ដ៏មានតម្លៃដែលអាចការពារទាំងអ្នកទិញ និងអ្នកលក់ក្នុងការធ្វើប្រតិបត្តិការដែលមានតម្លៃខ្ពស់។

សេវាកម្មនេះមានលក្ខណៈសាមញ្ញនោះទេ។ មុនពេលអ្នកលក់ផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យរបស់ពួកគេ ប្រាក់របស់អ្នកទិញត្រូវបានដាក់ក្នុងគណនីដែលធ្វើប្រតិបត្តិការដោយភាគីទីបីដែលឯករាជ្យ និងគួរឲ្យទុកចិត្ត ដោយត្រូវបានគេស្គាល់ថាជាភ្នាក់ងារសេវា escrow ។ ជាធម្មតា ភ្នាក់ងារសេវា escrow គឺជាធនាគារ ឬក្រុមហ៊ុនដែលត្រូវបានទទួលស្គាល់ផ្សេងណាមួយដែលមានទាំងសិទ្ធិ និងលទ្ធភាពក្នុងការទទួលខុសត្រូវលើទឹកប្រាក់។

បន្ទាប់មកទឹកប្រាក់ត្រូវបានរក្សាទុកដោយមានទំនុកចិត្ត រហូតដល់កិច្ចព្រមព្រៀងរវាងអ្នកទិញ និងអ្នកលក់ត្រូវបានបញ្ចប់យ៉ាងគាប់ចិត្ត កម្មសិទ្ធិត្រូវបានផ្ទេរដោយស្របច្បាប់ ហើយលក្ខខណ្ឌទាំងអស់នៃការលក់ត្រូវបានឯកភាព។

## សារៈសំខាន់នៃឯករាជ្យភាព

អ្វីដែលសំខាន់បំផុតអំពីភ្នាក់ងារសេវា escrow គឺថាពួកគេមិនធ្វើការក្រោមអ្នកទិញ ឬអ្នកលក់ទេ។ ពួកគេជាភ្នាក់ងារឯករាជ្យទាំងស្រុង។

សំខាន់ជាងនេះ ភ្នាក់ងារសេវា escrow មានការងារសំខាន់ៗចំនួនបី៖

- **រក្សាសុវត្ថិភាពទឹកប្រាក់របស់អ្នកទិញ**
- **ពិនិត្យមើលថាលក្ខខណ្ឌទាំងអស់នៃការលក់ត្រូវបានបំពេញ**
- **ផ្ទេរទឹកប្រាក់ឲ្យបានត្រឹមត្រូវទៅកាន់អ្នកលក់**

នៅពេលដែលទឹកប្រាក់ត្រូវបានដាក់ក្នុងគណនី escrow មិនថាអ្នកទិញ ឬអ្នកលក់គឺមិនអាចចូលប្រើវាបានឡើយ។ ទឹកប្រាក់អាចត្រូវបានដកពីគណនីដោយភ្នាក់ងារសេវា escrow តែប៉ុណ្ណោះ។

ដូច្នេះជាឧទាហរណ៍ អ្នកទិញអាចទទួលបានទឹកប្រាក់របស់ពួកគេមកវិញ ប្រសិនបើការលក់មិនបានជោគជ័យ ដោយសារលក្ខខណ្ឌមិនត្រូវបានបំពេញ។ ដូចគ្នានេះដែរ ដរាបណាអ្នកលក់បំពេញកាតព្វកិច្ចរបស់ខ្លួន អ្នកទិញមិនអាចគេចមិនបង់ប្រាក់សម្រាប់អចលនទ្រព្យនោះទេ។

## តើនៅពេលណាដែលស័ក្តិសមសម្រាប់ការប្រើសេវាកម្ម escrow?

ជាធម្មតាសេវាកម្ម Escrow ត្រូវបានប្រើប្រាស់សម្រាប់ការធ្វើប្រតិបត្តិការដែលមានតម្លៃខ្ពស់ ឬមានភាពស្មុគស្មាញ។ សេវាកម្មនេះត្រូវបានគេប្រើជាទូទៅសម្រាប់ប្រតិបត្តិការទិញលក់ដី និងទ្រព្យអាជីវកម្ម ព្រមទាំងផ្ទះ និងផ្ទះល្វែងក្នុងស្រុក។

សេវានេះជាជម្រើសដ៏ពេញនិយមសម្រាប់ការធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងការលក់ភាគហ៊ុន ឬមូលបត្រផ្សេងទៀត ដែលអាចផ្ទេរកម្មសិទ្ធិអាជីវកម្មទៅម្ចាស់ថ្មីបាន។

សេវាកម្ម escrow ដែលមានទំហំតូចក៏ត្រូវបានគេប្រើជាញឹកញាប់ក្នុងការលក់អនឡាញជាមួយអ្នកទិញដោយការដាក់ប្រាក់សម្រាប់ទិញក្នុងគណនី escrow រហូតដល់ពួកគេទទួលបានទំនិញ។



## តើនៅពេលណាដែលស័ក្តិសមសម្រាប់ការប្រើសេវាកម្ម escrow?

ជាធម្មតាសេវាកម្ម Escrow ត្រូវបានប្រើប្រាស់សម្រាប់ការធ្វើប្រតិបត្តិការដែលមានតម្លៃខ្ពស់ ឬមានភាពស្មុគស្មាញ។ សេវាកម្មនេះត្រូវបានគេប្រើជាទូទៅសម្រាប់ប្រតិបត្តិការទិញលក់ដី និងទ្រព្យអាជីវកម្ម ព្រមទាំងផ្ទះ និងផ្ទះល្វែងក្នុងស្រុក។

សេវានេះជាជម្រើសដ៏ពេញនិយមសម្រាប់ការធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងការលក់ភាគហ៊ុន ឬមូលបត្រផ្សេងទៀត ដែលអាចផ្ទេរកម្មសិទ្ធិអាជីវកម្មទៅម្ចាស់ថ្មីបាន។

សេវាកម្ម escrow ដែលមានទំហំតូចក៏ត្រូវបានគេប្រើជាញឹកញាប់ក្នុងការលក់អនឡាញជាមួយអ្នកទិញដោយការដាក់ប្រាក់សម្រាប់ទិញក្នុងគណនី escrow រហូតដល់ពួកគេទទួលបានទំនិញ។

## ស្វែងយល់បន្ថែមអំពីសេវាកម្ម escrow របស់ធនាគារ ប្រេដ

ក្នុងនាមជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ដែលគ្រប់គ្រងដោយនិយ័តករបរធនបាលកិច្ចរបស់ប្រទេសកម្ពុជា ធនាគារ ប្រេដ ខេមបូឌា ផ្តល់សេវាដ៏ល្អដោយមានការធានាជូនដល់អតិថិជន។

យើងខ្ញុំជាធនាគារដែលមានដើមទុនច្រើន និងគួរឲ្យទុកចិត្ត ដែលត្រូវបានគាំទ្រដោយធនាគារលំដាប់កំពូលមួយនៅក្នុងប្រទេសបារាំង ហើយជាផ្នែកមួយនៃក្រុមសម្ព័ន្ធធនាគារដ៏ធំបំផុតមួយក្នុងពិភពលោក ដូច្នេះយើងខ្ញុំមានហិរញ្ញវត្ថុដ៏រឹងមាំដែលអតិថិជនរបស់យើងខ្ញុំអាចពឹងផ្អែកបាន។

យើងខ្ញុំក៏មានក្រុមការងារដែលមានបទពិសោធ និងជំនាញដែលអាចផ្តល់យោបល់លើកិច្ចព្រមព្រៀងនៃសេវា escrow និងធានាថាប្រាក់ត្រូវបានបញ្ចេញនៅពេលដែលកិច្ចព្រមព្រៀងត្រូវបានបញ្ចប់យ៉ាងត្រឹមត្រូវ។ ជាធម្មតា ក្រុមការងារផ្នែកច្បាប់របស់យើងខ្ញុំក៏ចូលរួមផងដែរក្នុងការធានាថាសេវាកម្ម escrow ទាំងអស់របស់យើងខ្ញុំដំណើរការដោយរលូន និងមានប្រសិទ្ធភាព ហើយប្រាក់នោះត្រូវបានបញ្ចេញនៅពេលដែលលក្ខខណ្ឌបានព្រមព្រៀងទាំងអស់ត្រូវបានឯកភាព។

**នៅចាំអ្វីទៀត? សូមស្វែងយល់បន្ថែមពីសេវាកម្ម Escrow របស់ធនាគារ ប្រេដ ថ្ងៃនេះ។**

ទូរសព្ទមកឥឡូវនេះ | អ៊ីម៉ែល

លោកអ្នកក៏អាចពិភាក្សាជាមួយប្រធានផ្នែកទំនាក់ទំនងនៅសាខាធនាគារ ប្រេដ ខេមបូឌា ណាមួយ។

តាមដានយើងខ្ញុំសម្រាប់ព័ត៌មានបន្ថែម៖

**BRED Bank (Cambodia) Plc.** | Registration: 00002982 | Postal Code: 12210
Head Office: No. 30, Preah Norodom Boulevard, Sangkat Phsar Thmey 3, Khan Daun Penh, Phnom Penh, Cambodia.
Freephone: **1800 20 1234** | International: **+855 23 999 222** | **bredcambodia.com.kh**